# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣✽៤៤

# កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង០៩:០០នាទីនៅក្នុងរោងចក្រ ណាហ្គាតិស ខ បភើរេសិន លីមីតធីត អាស័យដ្ឋាន ផ្លូវជាតិលេខ០១ អគារទី០១ ភូមិព្រែកគ្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

## ១. សមាសភាពអ្នកចូលរួម

### ក. ភាគីតំណាងអោយក្រុមហ៊ុន

-លោក Nie Chaoliang (ប្រធានរោងចក្រ)

-លោក ប៊ុល រិទ្ធី (ប្រធានផ្នែករដ្ឋបាល)

### ខ. ភាគីតំណាងកម្មករនិយោជិតនិងតំណាងសហជីពមូលដ្ឋាន

១-អ្នកស្រី នង នីម ២-អ្នកស្រី សែម ចិន្តា ៣-អ្នកស្រី លី វណ្ណា ៤-អ្នកស្រី គុប ធីតា

៥-កញ្ញា ស៊ាងសុជាត ៦-អ្នកស្រី សុខ កុសល ៧-អ្នកស្រី ស៊ីម គុន្ធា ៨-អ្នកស្រី ស៊ុន សុខេង

៩-អ្នកស្រីប៉ាត់ ធឿន ១០-អ្នកស្រី ឡឿក ព៉ាន់ ១១-អ្នកស្រី ឈី ណារី ១២-លោក អ៊ុំ អន។

## ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរការងារនៅក្នុងរោងចក្រក្នុងរយៈពេល ០១ខែដោយចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ ដោយពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្ដល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្ដែងដោយទាំងតំណាងរោងចក្រ ក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោមៈ

១.រោងចក្របានឯកភាពផ្ដល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន៣០ដុល្លាក្នុង១ខែកំឡុងពេលព្យួរការងារ។

Scanned with CamScanner

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ សហជីពមូលដ្ឋាន និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃការចរចានិងគោរពតាមនិតិវិធីច្បាប់។

## ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១-រោងចក្រចាប់ផ្តើមព្យួរការងារ កម្មករនិយោជិត ចំនួន១៨២ នាក់។ ចាប់ផ្តើមពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ ។

២- រោងចក្រផ្តល់ប្រាក់ឈ្នួលគោល៣០ដុល្លាក្នុង១ខែក្នុងពេលព្យួរការងារ ។

៣-ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួររោងចក្រអនុញ្ញាតិអោយកម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១១:00 នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

### ក.ភាគីតំណាងកម្មករនិយោជិត និង តំណាងសហជីពមូលដ្ឋាន

១-អ្នកស្រី នង នីម ២-អ្នកស្រី សែម ចិន្តា ៣-អ្នកស្រី លី វណ្ណា ៤-អ្នកស្រី គុប ធីតា

៥-កញ្ញា ស៊ាងសុជាត ៦-អ្នកស្រី សុខ កុសល ៧-អ្នកស្រី ស៊ីម គុន្ធា ៨-អ្នកស្រី ស៊ុន សុខេង

៩-អ្នកស្រីប៉ាត់ ធឿន ១០-ឌឿក វ៉ាន់ ១១-អ្នកស្រី ឈី ណារី ១២-លោក អ៊ុំ អន។

### ខ.ភាគីប្រធានក្រុម

១-អ្នកស្រី ភុំ ស្រីលី ២-អ្នកស្រី ធន់ សុគន្ធា ៣-អ្នកស្រី អ៊ុំ សុភក្តិ ៤-អ្នកស្រី សុខ គា

Scanned with CamScanner

៥-អ្នកស្រី យុន សុខណាន    ៦-អ្នកស្រី សុខ សោភា

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

ព្រះរាជាណាចក្រកម្ពុជា

Scanned with CamScanner